# The Safe Delivery App is officially launched to support healthcare workers in Cambodia




*Picture: The International Version Animations in the Safe Delivery Application*

JICA IINeoC Project and Maternity Foundation have partnered up to launch a Khmer version of the Safe Delivery App – a mobile training tool and job aid for healthcare workers to ensure safer childbirths for mothers and newborns in Cambodia.

To secure proper training and support to healthcare workers, the Safe Delivery App is one of the best tools because it is handy, efficient, and innovative. The App is free and works offline. It is simple to use and also equipped with intuitive and animated instructions to guide healthcare workers in basic emergency obstetric and newborn care. It includes videos, quizzes, descriptions of practical procedures, and drug lists that midwives and healthcare workers can always refer to – either on the job, in their spare time, or as part of their training.

Maternity Foundation and JICA IINeoC Project have been collaborating to support the government with the development of the Khmer version of the Safe Delivery App since 2020. The rollout and implementation of the Khmer App across the country will kick off in 2021, led by JICA IINeoC Project and National Maternal Child Health Centre in close collaboration with the regional health authorities.

The Safe Delivery App is freely available on Google Play and in App Store:
**Google Play for Android:**
https://apps.apple.com/dk/app/safe-delivery/id985603707
**App store for iPhone:**
https://play.google.com/store/apps/details?id=dk.maternity.safedelivery&hl=en&gl=US
You can access the Khmer version from; Settings >> Version >> Cambodia

# កម្មវិធីលើទូរស័ព្ទដៃថ្មីជាភាសាខ្មែរ (New Khmer App) ដើម្បីគាំទ្រដល់បុគ្គលិកថែទាំសុខភាពក្នុងការផ្តល់សេវាការសម្រាលប្រកបដោយសុវត្ថិភាព

"គម្រោងលើកកម្ពស់ការថែទាំបន្តនៅកម្ពុជាផ្តោតលើការថែទាំស្ត្រី និងទារកក្នុងពេលសម្រាល និងក្រោយពេលសម្រាល (JICA IINeoC Project)" និង មូលនិធិផ្ទៃកសម្ពត (Maternity Foundation) បានចាប់ដៃគូសហការគ្នាបង្កើតកម្មវិធីការសម្រាលកូនដោយសុវត្ថិភាពលើទូរស័ព្ទដៃជាភាសាខ្មែរ (Safe Delivery App) ដែលជាឧបករណ៍ (Tools) បណ្តុះ បណ្តាល និងជំនួយស្មារតីដល់បុគ្គលិកថែទាំសុខភាព ដើម្បីធានាឲ្យបាននូវសុវត្ថិភាពសម្រាប់ម្តាយ និងទារកទើបនឹងកើត នៅក្នុងប្រទេសកម្ពុជា ។

ដើម្បីទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងការគាំទ្រដល់បុគ្គលិកថែទាំសុខភាព កម្មវិធីការសម្រាលកូនដោយសុវត្ថិភាពនេះ (Safe Delivery App) គឺជាឧបករណ៍ថ្មីដ៏ល្អបំផុតមួយដែលងាយស្រួលប្រើ មានប្រសិទ្ធិ-ភាព និងប្រកបដោយភាពច្នៃប្រឌិត។ កម្មវិធីនេះ (App) បានដាក់ឲ្យប្រើប្រាស់ដោយឥតគិតថ្លៃ ហើយដំណើរការនៃការប្រើប្រាស់កម្មវិធីនេះគឺមិនត្រូវការអ៊ីនធឺណេតទេ (Offline) ងាយស្រួលប្រើ ហើយការណែនាំមានលក្ខណៈរស់រវើក ដើម្បីណែនាំបុគ្គលិកថែទាំសុខភាពក្នុងការថែទាំបន្ទាន់ផ្នែកសម្ភព និងទារកទើបនឹងកើត ក៏ដូចជាការគ្រប់គ្រងស្ថាន-ភាពនៅពេលមានជម្ងឺ Covid-19 ។ កម្មវិធីនេះមានរួមបញ្ចូលទាំងវីដេអូ កម្រងសំណួរ ការពិពណ៌នាអំពីនីតិវិធីជាក់ស្តែង និង បញ្ជីឱសថដែលឆ្មប និងបុគ្គលិកថែទាំសុខភាពតែងតែយកជាឯកសារយោង នៅពេលបំពេញការងារ ពេលទំនេរ ឬក៏ជាផ្នែកមួយនៃការបណ្តុះបណ្តាលរបស់ពួកគាត់ ។

មូលនិធិផ្ទៃកសម្ពត(Maternity Foundation) និងគម្រោង JICA-IINeoC បាននឹងកំពុងសហការដើម្បីគាំទ្ររាជរដ្ឋាភិបាលតាម រយៈការអភិវឌ្ឍកម្មវិធីថ្មីលើទូរស័ព្ទដៃជាភាសាខ្មែរស្តីពីការសម្រាលកូនដោយសុវត្ថិភាព តាំងពីឆ្នាំ ២០២០ មកម្លេះ ។ ការដាក់ចេញឲ្យប្រើប្រាស់ និងអនុវត្តកម្មវិធីនេះ (App) ជាភាសាខ្មែរ នៅទូទាំងប្រទេសនឹងចាប់ផ្តើមនៅឆ្នាំ ២០២១ ដែលដឹកនាំដោយគម្រោង JICA-IINeoC និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរសុខាភិបាលក្នុងតំបន់ ក៏ដូចជា មូលនិធិផ្ទៃកសម្ពត (Maternity Foundation) ។

កម្មវិធី (App) នេះអាចទាញបានដោយសេរី និងឥតគិតថ្លៃនៅលើ

Google Play សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទ Android៖

https://play.google.com/store/apps/details?id=dk.maternity.safedelivery&hl=en&gl=US

និងនៅក្នុង App Store សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទ iOS៖

https://apps.apple.com/dk/app/safe-delivery/id985603707

ពេលបានទាញយកកម្មវិធីហើយ ដើម្បីបានជាភាសាខ្មែរសូមធ្វើការចុច៖ Setting>>Version>>Cambodia ជាការស្រេច ។